**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ:០៣៣/០៨ របក.អគគ**

**របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ តុលា ឆ្នាំ ២០០៨**
**របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត**

ក្នុងខែ តុលា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃពុធ ទី៨ ខែតុលា ឆ្នាំ២០០៨ នៅសណ្ឋាគារអាំងទែរ-កុងទីណង់តាល់

-ផ្ញើលិខិតចាត់តាំងមន្ត្រីប្រធានគម្រោងនៃអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចំនួន ២រូប ដើម្បីចូលរួមសិក្ខាសាលាស្តីពីការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃ៧ ដល់ទី ១០ ខែតុលា ឆ្នាំ២០០៨ នៅសណ្ឋាគារឆ្នេរថ្មី ក្រុងព្រះសីហនុ

-ផ្ញើលិខិតអញ្ជើញ ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃ ទី១៥ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ផ្ញើលិខិតអញ្ជើញ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្ររៀបចំផែនការតុលាការគំរូ នៅសណ្ឋាគារហ្គោលដឹនស៊ី ក្រុងព្រះសីហនុ នៅថ្ងៃទី២០- ២១ ខែតុលា ឆ្នាំ២០០៨

-ផ្ញើលិខិតជូនឯកឧត្តម ស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាប ក្នុងការរៀបចំកិច្ចប្រជុំស្តីពីការជ្រើសរើសមន្ត្រីបង្គោល ដើម្បីងាយស្រួលទំនាក់ទំនងទទួល និងផ្តល់ព័ត៌មាន ឬរបាយការណ៍ស្តីពីការអភិវឌ្ឍន៍លើការកែទម្រង់ ច្បាប់ និងតុលាការ នៅថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ៨:០០ ព្រឹក នៅខេត្តសៀមរាប

-ផ្ញើលិខិតស្នើសុំចូលជួបពិភាក្សាជាមួយនឹងតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីស្វែងយល់ អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជា នៅថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ១៥:០០

- ផ្ញើលិខិតស្នើសុំចូលជួបពិភាក្សាជាមួយនឹងតំណាងក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ូស្មាន់ (Ombudsman) នៅកម្ពុជានៅថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ៨ៈ៣០ នាទី។

**ខ. ការងារកំណែទម្រង់**

-ប្រជុំក្រុមការងារជាន់ខ្ពស់ប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃពុធ ទី៨ ខែតុលា ឆ្នាំ២០០៨ នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់

-ប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃ ទី១៥ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ១៤ៈ៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ធ្វើសិក្ខាសាលាស្តីពីការជ្រើសរើសមន្ត្រីបង្គោល ដើម្បីងាយស្រួលទំនាក់ទំនងទទួល និងផ្តល់ព័ត៌មាន ឬរបាយការណ៍ ស្តីពីការអភិវឌ្ឍន៍លើការកែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ៨ៈ០០ ព្រឹក នៅខេត្តសៀមរាប។

**គ. ផ្សេងៗ**

-ចូលរួមសិក្ខាសាលាស្តីពីការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃ៧ ដល់ ទី១០ ខែតុលា ឆ្នាំ២០០៨ នៅសណ្ឋាគារឆ្នេរថ្មី ក្រុងព្រះសីហនុ

-ចូលរួមប្រជុំអន្តរក្រសួង ស្ថាប័ន ដើម្បីពិភាក្សាលើសេចក្តីព្រាងទី២ របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨ ផយអជ ឆ្នាំ២០០៦-២០១០

-ទទួលជួបក្រុមការងារវាយតំលៃគម្រោង CCJAPIII នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨។

**២-សន្និដ្ឋាន**

ក្នុងខែ តុលា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ ទន្ទឹងនឹងការបន្តសកម្មភាពលើគម្រោង ដែលមានស្រាប់ដូចជាតុលាការគំរូ និងប្រព័ន្ធសូចនាករជាដើម កំពុងតែប្រឹងប្រែងដើម្បីឱ្យចេញជារូបរាងនូវគម្រោងសហប្រតិបត្តិការជាមួយគម្រោង GTZ ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ

-ផ្លាស់ប្តូរយោបល់ជាមួយនឹង DIHR ពាក់ព័ន្ធនឹងជំនួយដែល DANIDA បម្រុងជួយឧបត្ថម្ភការងារ របស់អង្គភាពគ្រប់គ្រងគម្រោង និងគម្រោងតុលាការគំរូ (Model Court) និងគម្រោងសូចនាករ និងការតាម ដាន (IMS)។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊ួង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង